
www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

# 1.07 ប៉មបាបិល

តាំងពីយូរយារណាស់មកហើយ មានទឹកជំនន់គ្របដណ្ដប់លើផែនដីទាំងមូល ដើម្បីកំចាត់មនុស្សអាក្រក់ទាំងអស់ដែលរស់នៅលើផែនដី ។ ព្រះទ្រង់បានមានបន្ទូលឲ្យណូអេសង់ទូកធំមួយដើម្បីជួយសង្គ្រោះខ្លួនគាត់ និងក្រុមគ្រួសារ និងសត្វជាច្រើន ។ ទឹកជំនន់មានរយៈពេលសែសិបថ្ងៃសែសិបយប់ ។ នៅពេលដីស្ងួតក្រុមគ្រួសាររបស់ណូអេបានចាកចេញពីទូក ។ កូនប្រុសរបស់គាត់ចាប់ផ្ដើមមានគ្រួសាររៀងៗខ្លួន ។ ច្រើនឆ្នាំបានកន្លងផុតទៅ ណូអេ មានចៅៗ និងចៅទួត ជាច្រើន ។ មានកូនជាច្រើនទៀតដែលកើតមកបន្ទាប់ពីនោះ ។ ហើយច្រើនឆ្នាំក្រោយមកមានមនុស្សជាច្រើននៅលើផែនដីម្ដងទៀត ។

នៅពេលនោះមនុស្សគ្រប់គ្នានៅលើផែនដីទាំងមូល និយាយភាសាដូចគ្នាតែមួយ ។ មនុស្សទាំងអស់ដែលរស់នៅលើផែនដី ឥឡូវកើតចេញពីក្រុមគ្រួសាររបស់កូនប្រុសទាំងបីរបស់លោកណូអេគឺ សិម ហាំ និងយ៉ាផេត ។ ជំនួសឲ្យការដែលពួកគេចង់បានកន្លែងរស់នៅផ្សេងពីគ្នា ដូចព្រះបានគ្រោងទុកនោះ គឺពួកគេចង់រស់នៅជិតៗគ្នាវិញ ។ ពួកគេបានបង្កើតគំរោងការមួយ ។

ប្រជាជននិយាយគ្នាថា" ចូរបង្កើតទីក្រុងមួយសម្រាប់ខ្លួនយើង! យើងថែមទាំងអាចធ្វើប៉មខ្ពស់ ដែលខ្ពស់ទៅដល់ឋានសួគ៌ ។ យើងនឹងមានភាពល្បីល្បាញ ។ យើងនឹងមិនចាំបាច់ត្រូវបែងចែកជាតំបន់ដាច់ដោយឡែក ដើម្បីរស់នៅដូចព្រះទ្រង់ចង់បាននោះទេ ។ យើងអាចបន្តរស់នៅជាមួយគ្នាបាន ។ វាជាជម្រើសរបស់យើង ។ យើងនឹងមិនត្រូវបែកគ្នាទេ ។

ព្រះដ៏ជាព្រះទ្រង់បានយាងចុះមកមើលក្រុងដែលពួកគេសង់ ។ ទ្រង់បានឃើញប៉មដែលពួកគេកំពុងសាងសង់ទៅលើមេឃ ។ ព្រះអម្ចាស់ទ្រង់បានមានបន្ទូលទៅកាន់អង្គទ្រង់ថា «យើងឃើញថាពួកគេទាំងអស់ជាមនុស្សតែមួយ ។ ពួកគេទាំងអស់ប្រើភាសាដូចគ្នា ។ ពួកគេអាចសំរេចនូវអ្វីដែលពួកគេចង់បានពីព្រោះពួកគេទាំងអស់គ្នាយល់ពីគ្នា។ នេះគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ ពួកគេកំពុងមិនស្ដាប់បង្គាប់យើង ដោយមិនចេញទៅរស់នៅតំបន់ផ្សេងៗទៀតនៃផែនដី ដូចដែលអ្វីដែលយើងចង់បាន ។ ឥឡូវនេះគ្មានអ្វីដែលពួកគេមិនអាចធ្វើបានទេ ។ ពួកគេនឹងនៅតែមិនស្ដាប់បង្គាប់យើង" ។

ព្រះដ៏ជាព្រះទ្រង់ក៏មានផែនការដែរ ។ ហើយផែនការរបស់ព្រះតែងតែឈ្នះ ។ ប្រជាជនបានគិតថាពួកគេអាចធ្វើអ្វីដែលពួកគេចង់ធ្វើបាន ។ ពួកគេគិតថាពួកគេអាចសាងសង់ទីក្រុងមួយ និងរស់នៅកន្លែងដែលពួកគេចង់នៅ ។ ប៉ុន្តែព្រះគឺជាអ្នកដែលមានអំណាចបំផុត ។ ទ្រង់មានវិធីក្នុងការផ្លាស់ប្រែផែនការដែលមនុស្សគ្រោងទុក ។

ព្រះទ្រង់មានបន្ទូលទៅកាន់អង្គទ្រង់ផ្ទាល់ថា "ចូរមក យើងចុះទៅផែនដី ហើយបំភាន់ភាសារបស់ពួកគេ ។ នៅពេលដែលពួកគេមិនអាចធ្វើការសន្ទនាជាមួយគ្នាបាន នោះពួកគេនឹងមិនអាចបន្តធ្វើគំរោងការសង់ទីក្រុងរបស់ពួកគេ ឬធ្វើអ្វីផ្សេងទៀតបានឡើយ" ។

នោះជាអ្វីដែលបានកើតឡើង ។ ប៉មនៅក្នុងទីក្រុងត្រូវបានគេស្គាល់ថាជាប៉ម "បាបិល" ។ ពាក្យថា «បាបិល» មានន័យថា «ច្របូកច្របល់» ។ ប្រជាជនត្រូវបញ្ឈប់ការសាងសង់នៅទីក្រុង ព្រោះពួកគេមិនអាចស្ដាប់គ្នាបាន ។ មនុស្សគ្រប់គ្នាកំពុងនិយាយភាសាផ្សេងៗគ្នា ។ ព្រះទ្រង់បានបណ្ដាលឲ្យ ពួកគេផ្លាស់ទីលំនៅទៅតំបន់ផ្សេងៗទៀតនៃផែនដី ។ កន្លែងនីមួយៗមានភាសាតាមតំបន់រៀងៗខ្លួន ។

នេះគ្រាន់តែជាអ្វីដែលព្រះបានគ្រោងទុករួចហើយ

**(លោកុប្បត្តិ ១១)**

## 1.07 ប៉មបាបិល - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន
## កំណត់សំគាល់

១) ព្រះទ្រង់បានបញ្ជូនទឹកជំនន់ដើម្បីបំផ្លាញមនុស្សអាក្រក់ៗនៅលើផែនដី ។ ព្រះទ្រង់បានត្រាស់ហៅបុរសសុចរិតម្នាក់ឈ្មោះថាណូអេឲ្យសាងសង់ទូកធំមួយ ដូចនេះណូអេ និងក្រុមគ្រួសារគាត់បានសង្គ្រោះ ។ ក្រោយពីទឹកជំនន់មកកូនៗលោកណូអេ ចាប់ផ្តើមមានគ្រួសាររៀងៗខ្លួន ។ ច្រើនឆ្នាំក្រោយមក មានមនុស្សកាន់តែច្រើនឡើង ច្រើនឡើងលើផែនដីម្តងទៀត ។

២) មនុស្សទាំងអស់និយាយភាសាតែមួយដូចគ្នា ។ ប្រជាជនក៏បានចាប់ផ្តើមបង្កើតគម្រោងកសាងទីក្រុង ទៅតាមចិត្តរបស់ពួកគេ ។ ពួកគេក៏បានចាប់ផ្តើមសាងសង់ប៉មខ្ពស់មួយ ។

៣) ព្រះទ្រង់បានទតឃើញនូវអ្វី ដែលពួកគេកំពុងធ្វើ ។ ទ្រង់បានឃើញថាប្រជាជនកំពុងតែមិនស្តាប់បង្គាប់ទ្រង់ ។ ទ្រង់ចង់ឲ្យពួកគេរស់នៅតំបន់ផ្សេងៗពាសពេញផែនដី ។

៤) ព្រះដ៏ជាព្រះទ្រង់បានបំភាន់ភាសារបស់ពួកគេ ។ នៅពេលពួកគេដឹងថាពួកគេមិនអាចជជែកគ្នាបាន គម្រោងសាងសង់ប៉ម និងទីក្រុងថ្មីត្រូវតែបញ្ឈប់ ។

៥) ព្រះទ្រង់បានបណ្តាលឲ្យប្រជាជនផ្លាស់ទៅតំបន់ផ្សេងៗគ្នានៃផែនដី ។ តំបន់នីមួយៗនឹងមានភាសាដូចគ្នាតាមតំបន់ ។ នេះគ្រាន់តែជាអ្វីដែលព្រះបានគ្រោងទុករួចមកហើយ ។

**សំណួរ:**

១) តើមនុស្សទាំងអស់នេះមានប្រភពមកពីនរណា ?
២) តើប្រជាជនមានគម្រោងធ្វើអ្វី?
៣) តើព្រះដ៏ជាព្រះទ្រង់មានផែនការអ្វីខ្លះសម្រាប់ពួកគេ?
៤) តើព្រះបានធ្វើអ្វី ដើម្បីឲ្យផែនការរបស់ទ្រង់អាចដំណើរការបាន?
៥) ក្រោយមកតើប្រជាជនទាំងអស់ត្រូវទៅណា?

**ចម្លើយ:**

១) មនុស្សទាំងអស់នេះមកពីណូអេ និងគ្រួសារកូនប្រុសរបស់គាត់ ។
២) ប្រជាជនចង់សាងសង់ទីក្រុងតាមចិត្តរបស់ពួកគេ ។
៣) ព្រះចង់ឲ្យពួកគេរស់នៅតំបន់ផ្សេងៗពាសពេញលើផែនដី ។
៤) ព្រះដ៏ជាព្រះទ្រង់បានបំភាន់ភាសារបស់ពួកគេ ដូច្នេះពួកគេមិនអាចយល់គ្នាបានទេ ។
៥) ប្រជាជនត្រូវផ្លាស់ទៅរស់នៅតំបន់ផ្សេងៗពាសពេញផែនដី ។


www.kidsofdestiny.org